

# ដំណើរការរៀបចំ

# សៀវភៅបណ្តុះបណ្តាលថ្នាក់ជាតិស្តីពីការពង្រឹងភាពអង់អាចសម្រាប់អ្នកប្រមូលសំណល់កែច្នៃ៖ បរិយាបន្ន សុវត្ថិភាព និងការរីកចម្រើន

ថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០២៥
ខេត្តបាត់ដំបង

រៀបចំបទបង្ហាញដោយ៖
លីម សេរីរ័ត្ន

# ដំណើរការនៃការរៀបចំ

### សេចក្តីព្រាងសៀវភៅ

រៀបចំសេចក្តីសៀវភៅបណ្តុះបណ្តាល
ដំបូងដែលបានពីការពិនិត្យឯកសារពាក់
ព័ន្ធ

### វគ្គបណ្តុះបណ្តាលសាកល្បង

ការកែសម្រួលពង្រាងសៀវភៅ និងការសាក
ល្បងវគ្គបណ្តុះបណ្តាលចំនួន ២ ជាមួយអ្នក
ប្រមូលសំណល់កែច្នៃ



### ការពិគ្រោះយោបល់

ការពិនិត្យឡើងវិញពីអ្នកពាក់
ព័ន្ធផ្សេងៗ

### សិក្ខាសាលា

សិក្ខាសាលាពិគ្រោះយោបល់
ជាមួយអ្នកជំនាញសំខាន់ៗ

# គោលបំណងនៃវគ្គបណ្តុះបណ្តាល



ដើម្បីពង្រឹងភាពអង់អាចដល់អ្នកប្រមូលសំណល់កែច្នៃ ជាមួយនឹង**ចំណេះដឹងជាក់ស្តែង និងបំណិនជីវិត៖** សុវត្ថិភាព ការរៀបចំផែនការហិរញ្ញវត្ថុ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការយល់ដឹងអំពីសិទ្ធិ

ដើម្បីគាំទ្រមាគ៌ាឆ្ពោះទៅរកបរិយាបន្នសង្គម សេដ្ឋកិច្ច និងស្ថាប័ន ដោយបំពាក់បំប៉នអ្នកប្រមូលសំណល់កែច្នៃ (IWCs) ឱ្យចូលរួមក្នុង**សេដ្ឋកិច្ចក្នុងប្រព័ន្ធ ចេះប្រើប្រាស់ ឧបករណ៍ឌីជីថល និងចូលរួមក្នុងបណ្តាញសហគមន៍**

# មេរៀនសំខាន់ៗ

មេរៀនគ្របដណ្តប់លើប្រធានបទសំខាន់ៗ ដូចខាងក្រោម៖



ការណែនាំ និងការស្គាល់គ្នា



ការបង្កើតក្តីស្រម៉ៃ



ផ្នែកនៃសង្គម (សិទ្ធិមនុស្ស និងសិទ្ធិការងារ)



ចំណេះដឹងផ្នែកហិរញ្ញវត្ថុ



សុខភាព និងសុវត្ថិភាពការងារ



ការបញ្ចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ



ឧបករណ៍ឌីជីថល



ឆ្ពោះទៅកាន់ក្តីស្រម៉ៃរបស់អ្នក

# មេរៀនទី ១៖ – ការណែនាំ និងការស្គាល់គ្នា

## គោលបំណងសំខាន់

ស្វាគមន៍អ្នកចូលរួម ណែនាំវគ្គ និងបង្កបរិយាកាសក្នុងការចែករំលែកការរំពឹងទុក និងសុវត្ថិភាពក្នុងការសិក្សា

## ខ្លឹមសារនៃមេរៀន

យល់ដឹងពីរបៀបវារៈ និងការរៀបចំភស្តុភារ, ដឹងពីគោលបំណង និងគោលការណ៍, ចែករំលែកការរំពឹងទុក និងការភ្ជាប់ទំនាក់ទំនង

## ឧបករណ៍បណ្តុះបណ្តាល

បទបង្ហាញ, ក្រដាសផ្ទាំងធំ ( flipcharts ), របៀបវារៈជាកម្រងរូបភាព, ប័ណ្ណឈ្មោះ, ដើមឈើនៃការរំពឹងទុក, ហ្វឺត

## សកម្មភាពសំខាន់ៗ

ការស្វាគមន៍ និងទិដ្ឋភាពទូទៅនៃរបៀបវារៈ ការណែនាំអំពីគោលការណ៍បណ្តុះបណ្តាល, លំហាត់បំបែកភាពស្ងៀមស្ងាត់ ( Icebreaker ) និងការចែករំលែកការរំពឹងទុក

## រយៈពេល

៣០ - ៤០ នាទី

# សកម្មភាព/ដំណើរការ



សកម្មភាពណែនាំខ្លួន

ការរំពឹងទុករបស់អ្នកចូលរួម និងការពិនិត្យមើលគោលបំណង

ការបង្ហាញរបៀបវារៈរយៈពេល ២ថ្ងៃ និងគោលការណ៍ស្នូលនៃការបណ្តុះបណ្តាល

# ខ្លឹមសារសំខាន់ៗ

- គោលបំណងនៃវគ្គបណ្តុះបណ្តាល
- គោលការណ៍ស្នូលសម្រាប់ការបណ្តុះបណ្តាល៖

## ការចូលរួមយ៉ាងសកម្ម

អ្នកចូលរួមត្រូវបានលើកទឹកចិត្តឱ្យចូលរួមពេញលេញក្នុងការពិភាក្សា និងសកម្មភាពនានា។ សំឡេង ទស្សនៈ និងបទពិសោធផ្ទាល់របស់ពួកគេ មានសារៈសំខាន់យ៉ាងខ្លាំងចំពោះដំណើរការសិក្សា។

## ការផ្ទុះបញ្ចាំងពីបទពិសោធផ្ទាល់ខ្លួន

វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំឡើង ដើម្បីផ្តល់កន្លែងសុវត្ថិភាពដែលអ្នកចូលរួមអាចផ្ទុះបញ្ចាំង និងចែករំលែកបទពិសោធផ្ទាល់ខ្លួនរបស់ពួកគេ ជាពិសេសទាក់ទងនឹងប្រធានបទបណ្តុះបណ្តាល (ឧទាហរណ៍៖ យេនឌ័រ ការត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយ ភាពធន់របស់សហគមន៍)។

## ការចូលរួមស្មើភាពគ្នា

អ្នកសម្របសម្រួលគួសបញ្ជាក់ពីសារៈសំខាន់នៃបរិយាបន្ន ដោយធានាថាអ្នកគ្រប់គ្នា ដោយមិនគិតពីប្រវត្តិ ភេទ ឬតួនាទី មានឱកាសស្មើគ្នាក្នុងការចូលរួមចំណែក ហើយសំឡេងរបស់ពួកគេត្រូវបានគេស្តាប់ឮ។

## គោរពគ្នាទៅវិញទៅមក

បរិយាកាសប្រកបដោយការគោរពត្រូវបានកំណត់ថាជារឿងចាំបាច់។ ត្រូវមានការគោរពគ្នាទៅវិញទៅមក ក្នុងអន្តរកម្មរវាងអ្នកចូលរួម និងអ្នកចូលរួម និងរវាងអ្នកចូលរួម និងអ្នកសម្របសម្រួល។

## មិនបង្កគ្រោះថ្នាក់

អ្នកសម្របសម្រួលពង្រឹងការប្តេជ្ញាចិត្តចំពោះការចូលរួមប្រកបដោយក្រមសីលធម៌ ដែលគ្មានអ្នកចូលរួមណាម្នាក់គួរមានអារម្មណ៍ថាខ្លួនអាចទទួលរងគ្រោះថ្នាក់ មិនត្រូវបានគោរព ឬត្រូវបានគេរើសអើងឡើយ ក្នុងអំឡុងពេលបណ្តុះបណ្តាលនេះ។

## រក្សាការសម្ងាត់

មានការធានាជូនអ្នកចូលរួមថា រឿងរ៉ាវផ្ទាល់ខ្លួន ឬព័ត៌មានរសើបដែលបានចែករំលែកអំឡុងពេលវគ្គនានា នឹងត្រូវបានរក្សាការសម្ងាត់។ នេះមានសារៈសំខាន់ណាស់សម្រាប់ការជំរុញទំនុកចិត្ត និងការលើកទឹកចិត្តឱ្យមានការសន្ទនាដោយស្មោះត្រង់។

# មេរៀនទី ២ – ការបង្កើតក្ដីស្រម៉ៃ

## គោលបំណងសំខាន់

គាំទ្រអ្នកចូលរួមផ្ដោះបញ្ជាំងពីបំណងប្រាថ្នារបស់ពួកគេ និងចាប់ផ្ដើមរៀបចំចក្ខុវិស័យផ្ទាល់ខ្លួនសម្រាប់អនាគត

## ខ្លឹមសារមេរៀន

ទទួលស្គាល់ភាពខ្លាំង និងទេពកោសល្យផ្ទាល់ខ្លួន បរិយាយពីក្ដីស្រម៉ៃ និងគោលដៅផ្ទាល់ខ្លួន និងកំណត់ជំហានតូចៗឆ្ពោះទៅរកការសម្រេចក្ដីស្រម៉ៃទាំងនោះ

## ឧបករណ៍បណ្ដុះបណ្ដាល

ក្រដាសគូររូប, ហ្វឺតពណ៌, ក្រដាសផ្ទាំងធំ, រូបភាពជំនួយ, សម្ភារៈគាំទ្រជាភាសាខ្មែរ

## សកម្មភាពសំខាន់ៗ

ការបង្កើតរូបភាពដែលមើលឃើញ/ការគូររូប ពិព័រណ៍គំនូរ ការពិភាក្សារួម

## រយៈពេល

៦០ – ៧០ នាទី

# សកម្មភាព/ដំណើរការ

## ការបង្កើតរូបភាពដែលមើលឃើញ/ការគូររូប៖



- *តើអ្នកមានក្តីសង្ឃឹមអ្វីខ្លះ សម្រាប់កូនៗរបស់អ្នក ? សម្រាប់គ្រួសារទាំងមូលរបស់អ្នក ?*
- *តើការងារនាពេលអនាគតរបស់អ្នកអាចជាអ្វី ឬតើអ្នកនឹងធ្វើអ្វី ?*
- *តើសុខភាពរបស់អ្នកយ៉ាងម៉េចដែរ ?*
- *តើអ្នកគិតថាអ្នកនឹងចេះអ្វីថ្មី ?*
- *តើអ្នកមានក្តីស្រម៉ៃអ្វីខ្លះ ? សម្រាប់ខ្លួនអ្នក និងគ្រួសាររបស់អ្នក ? និងសហគមន៍របស់អ្នក ?*



## ពិព័រណ៍គំនូរ និងការបង្ហាញ



## ការពិភាក្សារួម៖

តើអ្នកមានអារម្មណ៍យ៉ាងណា ?

តើអ្នកបានរកឃើញអ្វីថ្មីអំពីខ្លួនអ្នក ?

# ខ្លឹមសារសំខាន់ៗ

- **ការស្វែងយល់ពីអត្តសញ្ញាណ**
  អ្នកចូលរួមបង្ហាញពីខ្លួនឯងតាមរយៈរូបភាព ដើម្បីផ្តួចផ្តើមឆ្លុះបញ្ចាំងពីអត្តសញ្ញាណខ្លួនឯង
- **ការកំណត់បរិបទជីវិតបច្ចុប្បន្ន**
  គំនូរអំពីទិដ្ឋភាពសំខាន់ៗនៃជីវិតបច្ចុប្បន្នរបស់ពួកគេ —គ្រួសារ ការងារ ជំនាញ ចំណាប់អារម្មណ៍ និងធនធានផ្ទាល់ខ្លួន។
- **ការមើលឃើញក្តីស្រម៉ៃ (ចក្ខុវិស័យ)**
  គូររូបភាពអំពីក្តីសង្ឃឹម និងគោលដៅរបស់ពួកគេសម្រាប់អនាគត ដោយមានការណែនាំតាមរយៈសំណួររបស់អ្នកសម្របសម្រួលអំពីគ្រួសារ អាជីព ការរីកចម្រើនផ្ទាល់ខ្លួន សុខភាព និងការចូលរួមចំណែកក្នុងសហគមន៍
- **ការចែករំលែកក្នុងក្រុមធំ**
  ដាក់បង្ហាញគំនូររបស់ពួកគេ សង្កេតមើលផែនទីក្តីស្រម៉ៃរបស់អ្នកដទៃ និងចែករំលែកអត្ថន័យនៅពីក្រោយចក្ខុវិស័យរបស់ពួកគេ តាមការស្ម័គ្រចិត្ត
- **ការសង្ខេបត្រឡប់ដោយឆ្លុះបញ្ចាំង**
  បុគ្គលម្នាក់ៗពិភាក្សាអំពីអារម្មណ៍ ការយល់ដឹង និងការរកឃើញដែលទទួលបាន តាមរយៈដំណើរការច្នៃប្រឌិតនេះ។



# មេរៀនទី ៣ – ផ្នែកនៃសង្គមៈ សិទ្ធិមនុស្ស និងសិទ្ធិការងារ

## គោលបំណងសំខាន់

មេរៀននេះជួយឱ្យកម្មករប្រមូលសំណល់កៃច្នៃ ឱ្យយល់អំពីសិទ្ធិមូលដ្ឋានរបស់ពួកគេនៅកន្លែងធ្វើការ នៅទីសាធារណៈ និងនៅក្នុងសង្គម

## ខ្លឹមសារមេរៀន

- ហេតុអ្វីបានជាការងាររបស់អ្នកមានសារៈសំខាន់ ?
- ចំណុចអ្វីដែលធ្វើឱ្យការងាររបស់អ្នកមានលក្ខណៈពិសេស ?
- មូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស
- សិទ្ធិមនុស្សជាមូលដ្ឋាន
- ការយល់ដឹង និងការដោះស្រាយបញ្ហាប្រឈមផ្នែកសិទ្ធិមនុស្ស

## ឧបករណ៍បណ្តុះបណ្តាល

- ក្រដាសផ្ទាំងធំ (Flipcharts)
- រូបភាពបង្ហាញពីតួនាទីក្នុងសហគមន៍
- ក្រដាសស្អិត (Sticky notes)
- ឯកសារចែកជូនជាភាសាខ្មែរស្តីពីសិទ្ធិ និងសេវាកម្ម

## សកម្មភាពសំខាន់ៗ

- ការយល់ដឹងអំពីតម្លៃនៃការងាររបស់អ្នក
- ភពចម្លែក (Strange Planet)

## រយៈពេល

១០០ – ១២០ នាទី

# សកម្មភាព/ដំណើរការ

## ការយល់ដឹងអំពីតម្លៃនៃការងាររបស់អ្នក៖

### ការគូររូប/ការបង្ហាញរូបភាពបែបអន្តរកម្ម

តើអ្នកធ្វើអ្វីខ្លះ ក្នុងនាមជាអ្នកប្រមូលសំណល់កែច្នៃ? តើអ្នកធ្វើវានៅឯណា?

តើផលិតផលរបស់អ្នកទៅណា? តើអ្នកលក់ នៅឯណា?

តើអ្នកដឹងទេថាពួកគេយកទៅធ្វើអ្វី បន្ទាប់ពីទិញផលិតផលរបស់អ្នក?

តើនរណាទិញផលិតផលរបស់អ្នក?



### ការឆ្លុះបញ្ចាំងពីការចូលរួមចំណែកការងាររបស់អ្នកចូលរួមចំពោះបរិស្ថាន និងសេដ្ឋកិច្ច

## ការយល់ដឹងពីសិទ្ធិមនុស្សជាមូលដ្ឋាន និងសិទ្ធិការងារ

សកម្មភាព "ភពចម្លែក"



សិទ្ធិទទួលបានការងារ

សិទ្ធិទទួលបានសុខភាព

សិទ្ធិទទួលបានសុវត្ថិភាព

# ខ្លឹមសារសំខាន់ៗ៖ ការយល់ដឹងអំពីតម្លៃនៃការងាររបស់អ្នក៖

## ហេតុអ្វីការងាររបស់អ្នកសំខាន់

- អ្នកប្រមូលវត្ថុដែលអាចកែច្នៃប្រើប្រាស់ឡើងវិញរាប់រយពាន់តោនជារៀងរាល់ឆ្នាំ **ដោយជួយសង្គ្រោះសំណល់ជិត ៨%** របស់កម្ពុជាពីទីលានចាក់សំរាម
- អ្នកកាត់បន្ថយការបំពុល ការពារធនធានធម្មជាតិ និងរក្សាសហគមន៍ឱ្យស្អាត
- ជួយដល់អាជីវកម្មកែច្នៃក្នុងស្រុក និងរួមចំណែកដល់សេដ្ឋកិច្ចកម្ពុជា
- ការខិតខំប្រឹងប្រែងរបស់អ្នកជួយប្រទេសឱ្យបោះជំហានឆ្ពោះទៅរក**សេដ្ឋកិច្ចចក្រា**ដែលសំណល់ក្លាយជាធនធាន

## អ្វីដែលធ្វើឱ្យអ្នកពិសេស

- អ្នកមានជំនាញដែល**រៀនដោយខ្លួនឯង** និងដឹងពីសម្ភារៈដែលមានតម្លៃ
- អ្នកខិតខំធ្វើការ ទោះបីស្ថិតក្នុងស្ថានភាពលំបាក ដើម្បីផ្គត់ផ្គង់គ្រួសារ និងសហគមន៍របស់អ្នក
- អ្នកដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយបញ្ហាសំណល់ដែលកំពុងកើនឡើងនៅកម្ពុជា
- អ្នកគឺជា**កម្មករបរិស្ថាន** ជាវីរជនក្នុងទីក្រុង ដែលសមនឹងទទួលបានសុវត្ថិភាពខ្ពស់ ប្រាក់ចំណូលមានស្ថិរភាព និងការគោរពពីសាធារណជន

## ការកសាងការគោរព និងការទទួលស្គាល់

- អ្នកប្រហែលជាមិនពាក់ឯកសណ្ឋានទេ **ប៉ុន្តែអ្នកពាក់ការទទួលខុសត្រូវ**
- អ្នកប្រហែលជាមិនធ្វើការក្នុងការិយាល័យទេ **ប៉ុន្តែអ្នករក្សាផ្លូវឱ្យស្អាត**
- អ្នកប្រហែលជាមិនមានតួនាទីជាផ្លូវការទេ **ប៉ុន្តែការងាររបស់អ្នកមានតម្លៃពិតប្រាកដ**

# ខ្លឹមសារសំខាន់ៗ៖ សិទ្ធិមនុស្ស

| | |
|---|---|
| **មូលដ្ឋានគ្រឹះ៖** | • ជាសកល, ស្មើភាពគ្នា, ការពារសេចក្តីថ្លៃថ្នូរ, គ្មានការរើសអើង<br>• សេរីភាពនៃការគិត ការនិយាយ សាសនា ការងារសមរម្យ ការអប់រំ |
| **សិទ្ធិមូលដ្ឋាន៖** | • ជីវិត, សេរីភាព, ការប្រព្រឹត្តដោយស្មើភាព, ឯកជនភាព, ការអប់រំ, សេរីភាពពីការរើសអើង |
| **ក្របខណ្ឌការងារសមរម្យរបស់អង្គការពលកម្មអន្តរជាតិ (ILO)៖** | • ប្រាក់ឈ្នួលសមរម្យ, លក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាព, សេរីភាពក្នុងការបង្កើតសហជីព, ការការពារពីការរើសអើង, ការលុបបំបាត់ពលកម្មបង្ខំ/ពលកម្មកុមារ |
| **ការដោះស្រាយបញ្ហាប្រឈមផ្នែកសិទ្ធិមនុស្ស** | • **សកម្មភាពដែលអ្នកប្រមូលសំណល់កែច្នៃ (IWCs) អាចធ្វើបាន៖**<br>✓ រាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន (មេឃុំ/ចៅសង្កាត់ ប៉ូលិស ការិយាល័យស្រុក/ខណ្ឌ)<br>• ធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាល (អង្គការលីកាដូ, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា CCHR) សម្រាប់ជំនួយផ្លូវច្បាប់ ការតស៊ូមតិ និងការយកចិត្តទុកដាក់ពីប្រព័ន្ធផ្សព្វផ្សាយ<br>• ចូលរួមយន្តការច្បាប់ (តុលាការ ស្ថាប័នវិវាទការងារ គណៈកម្មាធិការសិទ្ធិមនុស្ស)<br>• ទាក់ទងប្រព័ន្ធផ្សព្វផ្សាយ/អ្នកសារព័ត៌មាន (រឿងរ៉ាវដែលបានចងក្រងជាឯកសារ វេទិកាអនឡាញ)។<br>• ប្រមូលផ្តុំដោយសន្តិវិធី (ញត្តិ យុទ្ធនាការ សិល្បៈ/ល្ខោនសម្រាប់ការយល់ដឹង) |

# មេរៀនទី ៤ – ចំណេះដឹងផ្នែកហិរញ្ញវត្ថុ

## គោលបំណងសំខាន់

បង្កើនការយល់ដឹងពីមូលដ្ឋានគ្រឹះនៃប្រាក់ចំណូល ការចំណាយ ការសន្សំ ការកាត់បន្ថយបំណុល ការគ្រប់គ្រងលុយប្រចាំថ្ងៃ រហូតដល់ការសន្សំរយៈពេលវែង ដើម្បីឯករាជ្យភាពហិរញ្ញវត្ថុយូរអង្វែង

## ខ្លឹមសារមេរៀន

កំណត់ប្រភពចំណូល និងការចំណាយទូទៅ, ការគ្រប់គ្រងថវិកា, ស្វែងយល់ពីយុទ្ធសាស្ត្រសន្សំ កំណត់គោលដៅហិរញ្ញវត្ថុផ្ទាល់ខ្លួនឱ្យបានល្អ

## ឧបករណ៍បណ្តុះបណ្តាល

គំរូថវិកាផ្ទាល់ខ្លួន គំរូថវិកាអាជីវកម្ម ប៊ិច ឬខ្មៅដៃ ក្រដាស ឬសៀវភៅកត់ត្រា ម៉ាស៊ីនគិតលេខ (តាមការស្ម័គ្រចិត្ត) ក្រដាសផ្ទាំងធំសម្រាប់លបង្ហាញ និមិត្តសញ្ញាដែលបានបោះពុម្ព

## សកម្មភាពសំខាន់ៗ

ការយល់ដឹងអំពីលុយ រៀបចំផែនការថវិកាគ្រួសារ រៀបចំផែនការថវិកាអាជីវកម្ម

## រយៈពេល

១២០ - ១៤០ នាទី

# សកម្មភាព/ដំណើរការ

## ការយល់ដឹងអំពីលុយ៖ ការប្រើប្រាស់រឿងរ៉ាវករណីសិក្សា និងការបង្ហាញ (ជាមួយនឹងរូបភាពតំណាង)



### រៀបចំផែនការថវិកាគ្រួសាររបស់អ្នក

គំរូថវិកាគ្រួសារ

| ប្រភេទ | ចំនួនប៉ាន់ស្មាន (ខែមុន) |
|---|---|
| ចំណូលសរុប | |
| – ចំណូលអាជីវកម្ម | |
| – ចំណូលផ្សេងៗ | |
| ចំណូលសរុប | |
| ចំណាយ | |
| – ម្ហូបអាហារ និងគ្រឿងទេស | |
| – ជួលផ្ទះ / លំនៅដ្ឋាន | |
| – ការដឹកជញ្ជូន/ធ្វើដំណើរ | |
| – ថ្លៃសាលារៀន | |
| – ភ្លើង / ទឹក | |
| – សុខភាព / ថ្នាំពេទ្យ | |
| – ការសងប្រាក់កម្ចី | |
| – ទូរស័ព្ទ / អ៊ីនធឺណិត | |
| – ផ្សេងៗ (បញ្ជាក់) | |
| ចំណាយសរុប | |
| ប្រាក់នៅសល់ / កង្វះខាត | |

### រៀបចំផែនការថវិកាអាជីវកម្មរបស់អ្នក

គំរូថវិកាអាជីវកម្ម

| ប្រភេទ | ចំនួនប៉ាន់ស្មាន (ខែមុន) |
|---|---|
| ចំណូលអាជីវកម្មសរុប | |
| – ការលក់ | |
| – ផ្សេងៗ | |
| ចំណូលសរុប | |
| ចំណាយ | |
| – ប្រាក់ខែផ្ទាល់ខ្លួន | |
| – ការដឹកជញ្ជូន (ប្រេងឥន្ធនៈ ថ្លៃឈ្នួល) | |
| – ឧបករណ៍ / សម្ភារៈ (ស្រោមដៃ ប៉ាវ) | |
| – ការជួសជុល / ថែទាំ | |
| – ថ្លៃតម្រៀប / ថ្លៃរក្សាទុក | |
| – អ្នកជួយ / ប្រាក់ឈ្នួលគាំទ្រ | |
| – សម្ភារៈសុវត្ថិភាព (ម៉ាស់ ស្បែកជើងកវែង) | |
| – ការសងប្រាក់កម្ចី (បើមាន) | |
| – ផ្សេងៗ (បញ្ជាក់) | |
| ចំណាយអាជីវកម្មសរុប | |
| ប្រាក់ចំណេញ / ខាត | |

# មេរៀនទី ៥ – សុខភាព និងសុវត្ថិភាពការងារ

## គោលបំណងសំខាន់

កំណត់ពីហានិភ័យសុខភាព និងសុវត្ថិភាព និងវិធីសាស្ត្រជាក់ស្តែងដើម្បីការពារខ្លួនទាំងផ្លូវកាយ និងផ្លូវចិត្ត

## ខ្លឹមសារមេរៀន

ស្គាល់គ្រោះថ្នាក់នៅកន្លែងការងារ យល់ដឹងពីការប្រើប្រាស់ និងការថែទាំឧបករណ៍ការពារសុវត្ថិភាពផ្ទាល់ខ្លួន (PPE), ជំនួយសង្គ្រោះបឋម និងការអនុវត្តអនាម័យជាមូលដ្ឋាន, ស្វែងយល់ពីយុទ្ធសាស្ត្រគ្រប់គ្រងសុខភាពផ្លូវចិត្ត និងភាពតានតឹង

## ឧបករណ៍បណ្តុះបណ្តាល

គំរូឧបករណ៍ PPE, ក្រដាសផ្ទាំងធំ, ជំនួយរូបភាព, ការសង្គ្រោះបឋម, ឯកសារចែកជូនជាភាសាខ្មែរ

## សកម្មភាពសំខាន់ៗ

ការយល់ដឹងអំពីសុខភាព និងសុវត្ថិភាពការងារ

ការឆ្លុះបញ្ចាំងពីបទពិសោធជីវិតពិត

លំហាត់ផ្លូវផ្តង (Marching exercise)

លំហាត់ដកដង្ហើម

## រយៈពេល

៩០–១០០ នាទី

# សកម្មភាព/ដំណើរការ

## ការយល់ដឹងអំពីសុខភាព និងសុវត្ថិភាពការងារ

ការបំផុសគំនិត និងការបង្ហាញណែនាំអំពីគំនិតនៃសុខភាព និងសុវត្ថិភាពការងារ (OHS)។

## ការឆ្លុះបញ្ចាំងពីបទពិសោធជីវិតពិត

ការពិភាក្សាបែបអន្តរកម្មអំពីការងាររបស់អ្នកចូលរួម និងហានិភ័យសុខភាព និងសុវត្ថិភាពដែលអាចកើតមាន

## លំហាត់ផ្ទួរផ្គង

## លំហាត់ដកដង្ហើម





# ខ្លឹមសារសំខាន់ៗ

## ហានិភ័យសុខភាព និងសុវត្ថិភាពទូទៅសម្រាប់អ្នកប្រមូលសំណល់កែច្នៃ

1. **ការប៉ះពាល់នឹងសម្ភារៈគ្រោះថ្នាក់៖"**
2. **ការខ្វះ ឬការស្ទាក់ស្ទើរក្នុងការពាក់ឧបករណ៍ការពារ**
3. **អគ្រាប្បួស៖** អគ្រាខ្ពស់នៃការដាច់រលាត់ ការមុត និងរបួសផ្សេងៗទៀត
4. **ហានិភ័យសុខភាព៖** បញ្ហាផ្លូវដង្ហើម ជំងឺស្បែក និងបញ្ហាសុខភាពផ្សេងៗទៀត
5. **លទ្ធភាពទទួលបានការថែទាំសុខភាពមានកម្រិតទាប៖** ទទួលបានការព្យាបាលតិចតួច ឬគ្មានសោះ
6. **អនាម័យមិនគ្រប់គ្រាន់**

1. **ម៉ោងធ្វើការយូរ**
2. **ប្រាក់ចំណូលទាប៖** ប៉ះពាល់ដល់លទ្ធភាពក្នុងការចំណាយលើការថែទាំសុខភាព និងអាហារូបត្ថម្ភសមរម្យ
3. **ភាពតានតឹងដោយសារកំដៅ** (Heat Stress)
4. **ពលកម្មកុមារ៖** ងាយរងគ្រោះ ដោយសារអាយុ និងកង្វះវិធានការការពារ
5. **ភាពតានតឹងផ្នែកចិត្តសាស្ត្រសង្គម៖** តែងតែជួបប្រទះការមាក់ងាយក្នុងសង្គម ភាពតានតឹង និងបញ្ហាសុខភាពផ្លូវចិត្ត
6. **ការការពារផ្លូវច្បាប់មានកម្រិត៖** ធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ ដែលខ្វះការការពារផ្លូវច្បាប់ និងសិទ្ធិការងារ

# ខ្លឹមសារសំខាន់ៗ៖ សារៈសំខាន់នៃការការពារសុវត្ថិភាពផ្ទាល់ខ្លួន

## ហេតុអ្វីបានជាឧបករណ៍ការពារសុវត្ថិភាពផ្ទាល់ខ្លួន (PPE) មានសារៈសំខាន់

- **ការពាររបួស** ពីវត្ថុមុតស្រួច កញ្ចក់បែក ឬសម្ភារៈគ្រោះថ្នាក់។
- **ការពាររាងកាយ និងសម្លៀកបំពាក់** ពីការចម្លងរោគ/ប្រឡាក់—សំខាន់ណាស់ព្រោះ អ្នកប្រមូលសំណល់កែច្នៃភាគច្រើនពាក់សម្លៀកបំពាក់ដូចគ្នាទាំងនៅកន្លែងធ្វើការ និងនៅផ្ទះ។
- **ការពារការដកដង្ហើម** ពីបាក់តេរី ធូលី និងភាគល្អិតគ្រោះថ្នាក់ដែលហោះហើរនៅជុំវិញទីលានចាក់សំរាម។
- **ការពារដៃឱ្យមានសុវត្ថិភាព** ដោយប្រើឧបករណ៍ជំនួសឱ្យការប៉ះពាល់សំណល់ផ្ទាល់។
- **ការពារជំងឺ**—ការចាក់ថ្នាំបង្ការ និង PPE កាត់បន្ថយហានិភ័យដូចជា តេតាណូស រលាកថ្លើម និងរលាកស្រោមខួរ។

## ការថែរក្សាសុខភាពផ្លូវចិត្ត៖ហេតុអ្វីវាសំខាន់

ប្រឈមនឹងភាពតានតឹងជារៀងរាល់ថ្ងៃពីការធ្វើការយូរម៉ោង បរិយាកាសមិនមានសុវត្ថិភាព និងប្រាក់ចំណូលមិនស្ថិតស្ថេរ។ សកម្មភាពតូចៗជាប្រចាំអាចជួយកែលម្អកម្លាំងផ្លូវចិត្ត និងសុខុមាលភាពទូទៅ។

## យុទ្ធសាស្ត្រដោះស្រាយបញ្ហាបុគ្គល

- លំហាត់ដកដង្ហើម និងការតាំងស្មារតី
- ការកត់ត្រាប្រចាំថ្ងៃ ឬការកត់ត្រាសំឡេង
- ទម្លាប់វិជ្ជមានប្រចាំថ្ងៃ
- ស្វែងរកជំនួយពីអ្នកជំនាញនៅពេលត្រូវក

## ការគាំទ្រសុខភាពផ្លូវចិត្តសហគមន៍

សុខភាពផ្លូវចិត្តប្រសើរឡើងនៅពេលសហគមន៍ជួយគ្នាទៅវិញទៅមក។ អ្នកប្រមូលសំណល់កែច្នៃ ក្លាយជាមនុស្សរឹងមាំនៅពេលពួកគេចែករំលែកបទពិសោធ និងមើលថែគ្នាទៅវិញទៅមក។

- ក្រុមគាំទ្រមិត្តភក្តិ / រង្វង់ជជែកពិភាក្សា
- ប្រព័ន្ធដៃគូ (Buddy System)
- ជញ្ជាំងវិជ្ជមានសហគមន៍
- ជំនួយសង្គ្រោះបឋមផ្នែកសុខភាពផ្លូវចិត្ត

# មេរៀនទី ៦ – ការបញ្ចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ

## គោលបំណងសំខាន់

យល់អំពីផ្លូវឆ្ពោះទៅរកការទទួលស្គាល់ជាផ្លូវការ ការទទួលបានកិច្ចគាំពារសង្គម និងការរៀបចំចងក្រងគ្នាជាក្រុម

## ខ្លឹមសារមេរៀន

យល់ដឹងពីអត្ថប្រយោជន៍ និងដំណើរការនៃការចុះបញ្ជីជាផ្លូវការ, ស្វែងយល់ពីកិច្ចគាំពារសង្គម, ស្វែងយល់ពីជម្រើសសម្រាប់ការចូលរួមសហគមន៍ ឬសមាគម, កំណត់ប្រព័ន្ធគាំទ្រក្នុងមូលដ្ឋាន

## ឧបករណ៍បណ្តុះបណ្តាល

ក្រដាសផ្ទាំងធំ, ជំនួយរូបភាព, គំរូទម្រង់ចុះបញ្ជី, ឯកសារចែកជូនជាភាសាខ្មែរ, សម្ភារៈសម្រាប់ការដើរតួ

## សកម្មភាពសំខាន់ៗ

ការពិភាក្សាពីការទទួលស្គាល់ជាផ្លូវការ, ដំណើរការចុះបញ្ជី, ការកំណត់ផែនទីសហគមន៍ និងសមាគម, ការកំណត់អត្តសញ្ញាណប្រព័ន្ធគាំទ្រ និងការរៀបចំផែនការសកម្មភាពផ្ទាល់ខ្លួន

## រយៈពេល

១០០–១២០ នាទី

# សកម្មភាព/ដំណើរការ

| ១ | ២ | ៣ |
|---|---|---|
| **ការពិភាក្សាពីការទទួលស្គាល់ជាផ្លូវការ** | **បទបង្ហាញ/ចែករំលែកពីអ្នកជំនាញ** | **ការកំណត់ផែនទី និងការរៀបចំផែនការ** |
| ការពិភាក្សា៖ "តើអ្នកគិតថា អ្វីជាការងារក្នុងប្រព័ន្ធ និងការងារក្រៅប្រព័ន្ធ?" | ចែករំលែកអំពីដំណើរការចុះបញ្ជី និងការគាំទ្រកិច្ចគាំពារសង្គម | ការកំណត់ផែនទីសហគមន៍ និងសមាគម, ការកំណត់អត្តសញ្ញាណប្រព័ន្ធគាំទ្រ និង ការរៀបចំផែនការសកម្មភាពផ្ទាល់ខ្លួន |







# ខ្លឹមសារសំខាន់ៗ

## ការងារក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ

១ ការងារក្នុងប្រព័ន្ធ
- ទទួលស្គាល់ដោយរដ្ឋាភិបាល, មានស្ថិរភាព, អាចទទួលបានហិរញ្ញប្បទាន

២ ការងារក្រៅប្រព័ន្ធ
- គ្មានអត្តសញ្ញាណប័ណ្ណ, គ្មានកិច្ចសន្យា, គ្មានការការពារ

៣ អត្ថប្រយោជន៍នៃការចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ (Formalization)
- ការគោរព, ប្រាក់ចំណូលមានស្ថិរភាព, លទ្ធភាពទទួលបានសេវាកម្ម។

៤ បញ្ហាប្រឈម
- ឯកសារ, ការភ័យខ្លាចពន្ធ, ប្រាក់ចំណូលមានកម្រិត។

## ផ្លូវ/ច្រកនៃការចុះបញ្ជី

តាមទូរស័ព្ទ ឬប្រព័ន្ធអនឡាញ

ស្ថាប័នថ្នាក់ក្រោមជាតិ

ដៃគូធនាគារ

មណ្ឌលចុះបញ្ជីចល័ត

## ឯកសារដែលត្រូវការ

| | | |
|---|---|---|
| អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | លិខិតបញ្ជាក់ទីលំនៅ | លិខិតបញ្ជាក់ការងារ / អាជីវកម្ម |
| រូបថតទំហំលិខិតឆ្លងដែន | ថ្លៃចុះបញ្ជីអាជីវកម្ម | |

វិញ្ញាបនបត្រចេញជូនក្នុងរយៈពេល ១ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការពិនិត្យផ្ទៀងផ្ទាត់។

# ខ្លឹមសារសំខាន់ៗ (ត)

## ការទទួលបានកិច្ចគាំពារសង្គម

**អត្ថប្រយោជន៍នៃបណ្ណក្រីក្រ / បណ្ណសមធម៌ (ID Poor / Equity Card)៖**

- សេវាថែទាំសុខភាពដោយឥតគិតថ្លៃនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ
- ការផ្ទេរប្រាក់ឧបត្ថម្ភ (សម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ ឆ្នាំ)
- អាហារូបករណ៍ និងការគាំទ្រការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការផ្ទេរប្រាក់ឧបត្ថម្ភក្នុងគ្រាអាសន្ន (ឧទាហរណ៍៖ ជំងឺកូវីដ-១៩)

**ដំណើរការ៖** ការស្នើសុំពីគ្រួសារ → ការសម្ភាសន៍ → ការផ្ទៀងផ្ទាត់ដោយក្រុមប្រឹក្សា → ការចែកជូនបណ្ណសមធម៌

## ការចុះបញ្ជី ប.ស.ស. (សម្រាប់បុគ្គលស្វ័យនិយោជន៍)

- ចុះឈ្មោះតាមប្រព័ន្ធអនឡាញ ឬនៅការិយាល័យ ប.ស.ស.
- ឯកសារ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, វិញ្ញាបនបត្រចុះបញ្ជីសហគ្រាសក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ភាគទាន៖ ១៥.៦០០ រៀល/ខែ ក្នុងមួយនាក់
- អត្ថប្រយោជន៍៖ ការព្យាបាល និងថែទាំសុខភាព, ប្រាក់បំណាច់មាតុភាព, ប្រាក់វិភាជន៍បូជាសព (ប្រាក់ឧបត្ថម្ភបុណ្យសព)

## បណ្ណអាទិភាព (មូលនិធិសមធម៌សុខាភិបាល - HEF)

- សម្រាប់គ្រួសារដែលខកខានការស្ទង់មតិអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ID Poor)
- ចេញជូនអំឡុងពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ
- ផ្តល់អត្ថប្រយោជន៍មូលនិធិសមធម៌សុខាភិបាល (HEF) រហូតដល់ការស្ទង់មតិលើកក្រោយ
- តម្រូវឱ្យមានលិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន

## ការកសាងបណ្តាញសហគមន៍

- កសាងទំនាក់ទំនងជាមួយអ្នកប្រមូលសំណល់កែច្នៃផ្សេងទៀត
- បង្កើតក្រុមសន្សំប្រាក់/ក្រុមគាំទ្រ
- ផ្សារភ្ជាប់ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន
- សហការជាមួយសហគមន៍/សហករណ៍ សហជីព និងអង្គការមិនមែនរដ្ឋាភិបាល

# មេរៀន៧ – ឧបករណ៍ឌីជីថល

## គោលបំណងសំខាន់

ស្វែងយល់ពីរបៀបដែលទូរស័ព្ទដៃ និងប្រព័ន្ធឌីជីថលអាចគាំទ្រដល់ការងារការទំនាក់ទំនង និងលទ្ធភាពទទួលបានហិរញ្ញវត្ថុ

## ខ្លឹមសារមេរៀន

កំណត់ឧបករណ៍ឌីជីថលទូទៅដែលប្រើប្រាស់ក្នុងជីវិតប្រចាំថ្ងៃ, មុខងារនៃទូរស័ព្ទដៃ និងកម្មវិធី (Apps), ហ្វឹកហាត់ប្រើប្រាស់ឧបករណ៍ឌីជីថលសម្រាប់ការទំនាក់ទំនង ការមើលផែនទី និងការគ្រប់គ្រងប្រាក់, កសាងទំនុកចិត្តក្នុងការប្រើប្រាស់សេវាឌីជីថល

## ឧបករណ៍បណ្ដុះបណ្ដាល

ទូរស័ព្ទដៃ (ពិត ឬគំរូ), រូបភាពថតពីអេក្រង់ដែលបានបោះពុម្ព, ក្រដាសផ្ទាំងធំ, សៀវភៅណែនាំជាភាសាខ្មែរ, សម្ភារៈសម្រាប់ការដើរតួ។

## សកម្មភាពសំខាន់ៗ

ការបំផុសគំនិតពីឧបករណ៍ឌីជីថល, ការឆបោកតាមអនឡាញ, ការឆ្លុះបញ្ចាំងពីទំនុកចិត្តផ្នែកឌីជីថល។

## រយៈពេល

៦០–៩០ នាទី

# សក្ដានុពល/ដំណើរការ

ការបំផុសគំនិតអំពីឧបករណ៍ឌីជីថល និងការណែនាំអំពីឧបករណ៍ឌីជីថល






ការកំណត់ពីការឆបោកតាមអនឡាញ




&work from home)!

t.me/FakeCompanyJob]

Telegram:
@Job_CambodiaHR

ការឆ្លុះបញ្ចាំងពីទំនុកចិត្តផ្នែកឌីជីថល



# ខ្លឹមសារសំខាន់ៗ

## ទិដ្ឋភាពទូទៅនៃឧបករណ៍ឌីជីថល

ទូរស័ព្ទស្មាតហ្វូន៖ ការហៅទូរស័ព្ទ, ការផ្ញើសារ, អ៊ីនធឺណិត, កម្មវិធី (Apps), ផែនទី

ថេប្លេត៖ អេក្រង់ធំជាង, ការអាន, វីដេអូ

កុំព្យូទ័រយួរដៃ/លើតុ៖ ការងារ, អ៊ីមែល, ការស្វែងរកទិន្នន័យ, ការបោះពុម្ព

នាឡិកាឆ្លាតវៃ/ឧបករណ៍តាមដានសុខភាព៖ ការតាមដានសុខភាព, ការជូនដំណឹង

ទូរទស្សន៍ឆ្លាតវៃ៖ ភ្ជាប់អ៊ីនធឺណិតសម្រាប់ YouTube, Netflix, ព័ត៌មាន

## ហេតុអ្វីអក្ខរកម្មឌីជីថលមានសារៈសំខាន់

- រក្សាទំនាក់ទំនង (Facebook, Telegram, Messenger)
- ទទួលបានសេវាកម្ម (បណ្ណាគ្រីក្រ, ព័ត៌មានសុខភាព, បច្ចុប្បន្នភាពពីរដ្ឋាភិបាល)
- រៀនជំនាញថ្មីៗ (វីដេអូ, ការបណ្តុះបណ្តាលតាមអនឡាញ)
- បង្កើនឱកាស (ការងារ, ការលក់វត្ថុធាតុដើមកែច្នៃ, បណ្តាញទំនាក់ទំនង)
- រក្សាសុវត្ថិភាព (សម្គាល់ដឹងពីការឆបោក, ការពារឯកជនភាព)

# ខ្លឹមសារសំខាន់ៗ (ត)

## ហ្វេសប៊ុក (Facebook) សម្រាប់អ្នកប្រមូលសំណល់កែច្នៃ

- ទំនាក់ទំនងជាមួយគ្រួសារ និងមិត្តភ័ក្តិ
- ចូលរួមក្រុមសហគមន៍/ក្រុមការងារ (អ្នករើសអេតចាយ, អ្នកទិញ, ការជូនដំណឹងក្នុងមូលដ្ឋាន)
- ទទួលបានព័ត៌មាន និងបច្ចុប្បន្នភាព (សុខភាព, អាកាសធាតុ, កម្មវិធីអត្តសញ្ញាណកម្ម)
- ផ្សព្វផ្សាយការងារ (ផ្សាយពីសម្ភារៈ, សេវាកម្ម, រឿងរ៉ាវជោគជ័យ)
- ចូលរួមការបណ្តុះបណ្តាល/កិច្ចប្រជុំតាមអនឡាញ

## តេលេក្រាម (Telegram) សម្រាប់អ្នកប្រមូលសំណល់កែច្នៃ

- ការផ្ញើសារ៖ អក្សរ, សំឡេង, រូបថត, វីដេអូ
- ការជជែកជាក្រុម និងឆានែលសម្រាប់បច្ចុប្បន្នភាពសហគមន៍/ការងារ
- ទទួលបានការជូនដំណឹងពីរដ្ឋាភិបាល/អង្គការ (អាកាសធាតុ, សុខភាព, ការចុះឈ្មោះអត្តសញ្ញាណប័ណ្ណ)
- ផ្សព្វផ្សាយសេវាកម្ម និងសម្ភារៈ
- វីដេអូបណ្តុះបណ្តាល, សៀវភៅណែនាំ, ការជជែកសួរ-ឆ្លើយ (Q&A)
- **គន្លឹះសុវត្ថិភាព៖** ការពារទូរស័ព្ទ, ចូលរួមក្រុមដែលជឿទុកចិត្ត, ជៀសវាងការចែករំលែកព័ត៌មានផ្ទាល់ខ្លួន

## សេវាធនាគារតាមទូរស័ព្ទ (Mobile Banking)

### អត្ថប្រយោជន៍សម្រាប់អ្នកប្រមូលសំណល់កែច្នៃ៖

- *សុវត្ថិភាព៖ កាត់បន្ថយហានិភ័យនៃការលួច*
- *ភាពងាយស្រួល៖ កាត់បន្ថយការធ្វើដំណើរទៅធនាគារ*
- *សន្សំពេលវេលា និងថវិកា*
- *កសាងកំណត់ត្រាហិរញ្ញវត្ថុ/ភាពជឿជាក់*
- *ការគ្រប់គ្រងការចំណាយ/ការសន្សំបានល្អប្រសើរ*
- *លទ្ធភាពទទួលបានឥណទាន ការធានារ៉ាប់រង និងសេវាកម្មផ្សេងៗ*

## សុវត្ថិភាពឌីជីថល

### ហានិភ័យ៖ ការបោកប្រាស់, ការលួចបន្លំទិន្នន័យ (Phishing), ខ្លឹមសារដែលបង្គ្រោះថ្នាក់, ការយាយី

### ការការពារ៖

- *កុំចែករំលែកអត្តសញ្ញាណប័ណ្ណ ពាក្យសម្ងាត់ ឬព័ត៌មានលម្អិតធនាគារ*
- *ប្រើពាក្យសម្ងាត់ដែលរឹងមាំ*
- *ការប្រើប្រាស់បណ្តាញសង្គមដោយសុវត្ថិភាព (មិត្តភក្តិដែលជឿទុកចិត្ត, ការបង្ហោះប្រកបដោយការគោរព)*

អំពើហិង្សាលើយេនឌ័រតាមប្រព័ន្ធបច្ចេកវិទ្យា៖ ការយាយី, ការគំរាមកំហែង, ការតាមដាន, ការឆបោកផ្តោតលើអ្នកប្រមូលសំណល់កែច្នៃជាស្ត្រី

# មេរៀនទី ៨ – ការសម្រួចក្តីស្រមៃរបស់អ្នក

## គោលបំណងសំខាន់

ឆ្លុះបញ្ចាំងពីការរៀនសូត្រ លទ្ធភាពនាពេលអនាគត និងកំណត់ជំហានបន្ទាប់ ដើម្បីការរីកចម្រើនផ្ទាល់ខ្លួន និងជាសមូហភាព

## ខ្លឹមសារមេរៀន

ឆ្លុះបញ្ចាំងពីវឌ្ឍនភាពផ្ទាល់ខ្លួន និងការរៀនសូត្រ, ពិនិត្យមើលគោលដៅ និងផ្លូវនាពេលអនាគត, កំណត់ធនធាន និងបណ្តាញសម្រាប់ការគាំទ្របន្ត និងពង្រឹងសាមគ្គីភាពក្រុម និងការលើកទឹកចិត្ត

## ឧបករណ៍បណ្តុះបណ្តាល

ក្រដាសផ្ទាំងធំ, ហ្វឺត, ក្តីស្រមៃ, សន្លឹកឆ្លុះបញ្ចាំងជាភាសាខ្មែរ, សម្ភារៈសម្រាប់ថតរូបជាក្រុម។

## សកម្មភាពសំខាន់ៗ

ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន, ការគូររូបផ្លូវនៃក្តីស្រមៃ, ការចែករំលែកជាក្រុម និងការអបអរសាទរ, ការកំណត់ផែនទីធនធាន និងជំហានបន្ទាប់ និងពិធីបិទ

## រយៈពេល

១០០–១១០ នាទី




# សកម្មភាព/ដំណើរការ

១ **ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន**

តើអ្នកបានរៀនអ្វីខ្លះក្នុងរយៈពេល ២ ថ្ងៃកន្លងមកនេះ?

២ **ការគូររូបផ្លូវនៃក្តីស្រម៉ៃ**

យោងទៅលើគំនូរដែលអ្នកចូលរួមបានធ្វើនៅពេលចាប់ផ្តើម។ សុំឱ្យពួកគេបន្ថែមគំនូរបន្ថែមទៀត ប្រសិនបើមាន បន្ទាប់ពីការរៀនសូត្រថ្មី។

៣ **សំណួរឆ្លុះបញ្ចាំង**

- តើអ្នកបានរៀនអ្វីខ្លះរហូតមកដល់ពេលនេះ ដែលអាចជួយអ្នកឱ្យសម្រេចក្តីស្រម៉ៃរបស់អ្នក?
- តើជំហានតូចៗអ្វីខ្លះដែលអ្នកអាចអនុវត្តបន្ទាប់ទៀត ឆ្ពោះទៅសម្រេចគោលដៅរបស់អ្នក?
- តើមានជំនាញ ឬឧបករណ៍អ្វីខ្លះដែលអ្នកនៅតែត្រូវការរៀន ឬទទួលបាន?
- តើនរណា ឬកន្លែងណាដែលអ្នកអាចទៅរកជំនួយ ឬធនធានដែលអ្នកត្រូវការ?
- តើគំនូរដែលបានធ្វើបច្ចុប្បន្នភាពរបស់អ្នកបង្ហាញពីវឌ្ឍនភាព និងផែនការរបស់អ្នកយ៉ាងដូចម្តេច?

៤ **ការចែករំលែកជាក្រុម និងការអបអរសាទរ**

# ខ្លឹមសារសំខាន់ៗ

## វឌ្ឍនភាព និងការរីកចម្រើន

- រីកចម្រើន រៀនសូត្រ និងទទួលបានជំនាញថ្មីៗ—សូមទទួលស្គាល់ និងអបអរសាទរចំពោះវឌ្ឍនភាព

## ក្តីស្រម៉ៃដែលអាចសម្រេចបាន

- ក្តីស្រម៉ៃរបស់អ្នកគឺជាការពិត និងអាចសម្រេចបាន—រាល់ក្តីស្រម៉ៃចាប់ផ្តើមដោយជំហានតូចៗ និងជាក់ស្តែង

## ការគាំទ្រសហគមន៍

- អ្នកមិននៅម្នាក់ឯងទេ—សហគមន៍របស់អ្នកគឺជាប្រភពនៃកម្លាំង ការគាំទ្រ និងភាពធន់រួមគ្នា។

## តម្លៃ និងការទទួលស្គាល់

- ការងាររបស់អ្នក សំឡេងរបស់អ្នក និងភាពខ្លាំងរបស់អ្នកមានសារៈសំខាន់។ អ្នកសមនឹងទទួលបានការទទួលស្គាល់ និងមោទនភាព

## ក្តីសង្ឃឹម និងគោលបំណង

- បន្តក្តីសង្ឃឹម កម្លាំង និងការរួបរួម—ដំណើររបស់អ្នកនៅបន្តជាមួយនឹងពន្លឺ និងគោលបំណង



# ការអនុវត្តសាកល្បង៖

## សង្ខេបពីមេរៀនដែលទទួលបាន និងការអនុវត្តល្អ

# និន្នាការទូទៅនៃវគ្គបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលសាកល្បងរយៈពេល ២ថ្ងៃ ចំនួន ២លើក បានរៀបចំឡើងសម្រាប់អ្នកប្រមូលសំណល់កែច្នៃ ៖ មានអ្នកចូលរួម ២៥នាក់ នៅ រាជធានីភ្នំពេញ និង ៣១នាក់ នៅខេត្តបាត់ដំបង។

## វិធីសាស្ត្របែបចូលរួម

ជំរុញការចូលរួមពីសិក្ខាកាម តាមរយៈការគូររូប ការពិភាក្សាក្រុម និងការបង្ហាញជាក់ស្តែង។

## ការផ្តោតលើការពង្រឹងភាពអង់អាច

ផ្តោតលើការកសាងទំនុកចិត្ត ចំណេះដឹង និងជំនាញសម្រាប់ការតស៊ូមតិ ដើម្បីសិទ្ធិ និងការកែលម្អជីវភាពរស់នៅ

# មេរៀនដែលទទួលបាន និងការអនុវត្តល្អ – ខ្លឹមសារ

## ១ ឧបករណ៍ហិរញ្ញវត្ថុសម្គាល់

សម្ភារៈ ចំណេះដឹងផ្នែកហិរញ្ញវត្ថុត្រូវការការសម្រួលយ៉ាងសំខាន់ ជាមួយនឹងការគាំទ្រការគណនា។ តារាងគួរប្រើអក្សរតិចតួច រូបភាពច្បាស់លាស់ និងផ្តល់ឧទាហរណ៍ជាជំហានៗ ដែលអ្នកចូលរួមអាចអនុវត្តបានដោយខ្លួនឯង។

## ២ ការអប់រំសិទ្ធិតាមរយៈរូបភាព

វគ្គស្តីពីសិទ្ធិមនុស្ស ទាមទាររូបភាពច្បាស់លាស់ និងពាក់ព័ន្ធនឹងវប្បធម៌ ដែលបង្ហាញពីស្ថានភាពជាក់ស្តែង ដែលអ្នកប្រមូលសំណល់កែច្នៃ ជួបប្រទះ។ គំនិតអរូបីត្រូវតែផ្អែកលើឧទាហរណ៍ជាក់ស្តែងពីជីវិតការងារប្រចាំថ្ងៃរបស់ពួកគេ។

## ៣ គម្លាតអក្ខរកម្មឌីជីថល និងអាទិភាពសុវត្ថិភាពឌីជីថល

ការបណ្តុះបណ្តាលស្តីពីសុវត្ថិភាពនៃប្រព័ន្ធឌីជីថល ជាពិសេស សារក្លែងក្លាយ និង ការលួចបន្លំ មានភាពពាក់ព័ន្ធយ៉ាងខ្លាំង សម្រាប់គ្រប់ក្រុម។ នៅពេលដែលការប្រើប្រាស់ទូរស័ព្ទកើនឡើង ការការពារអ្នកចូលរួមពីការកេងប្រវ័ញ្ចហិរញ្ញវត្ថុគឺជារឿងសំខាន់។

## ៤ ការពង្រឹងការបណ្តុះបណ្តាល OHS

ខ្លឹមសារស្តីពី សុខភាព និងសុវត្ថិភាពការងារ ត្រូវបានកែលម្អយ៉ាងខ្លាំងជាមួយនឹងការបង្ហាញ ឧបករណ៍ការពារសុវត្ថិភាពផ្ទាល់ខ្លួនជាក់ស្តែង និងព័ត៌មានតម្លៃក្នុងស្រុក

# មេរៀនដែលទទួលបាន និងការអនុវត្តល្អ - បរិយាបន្ន និងបណ្ដាញទំនាក់ទំនង

លើសពីការកសាងជំនាញ វគ្គបណ្ដុះបណ្ដាលបានបង្កើតកន្លែងដ៏មានតម្លៃសម្រាប់ការតភ្ជាប់ទំនាក់ទំនង"ពង្រឹងសាមគ្គីភាព និងសកម្មភាពរួមគ្នាក្នុងចំណោមអ្នកប្រមូលសំណល់កែច្នៃក្រៅប្រព័ន្ធ។

## ភាពជាដៃគូជាមួយ IDEA

វាគ្មិនមកពី IDEA បានពង្រឹងការយល់ដឹងរបស់អ្នកចូលរួមយ៉ាងខ្លាំងអំពីសិទ្ធិរបស់ពួកគេ និង កិច្ចគាំពារសង្គម ដែលមាន។ ការរៀនអំពីប្រព័ន្ធគាំទ្រផ្លូវការ បានផ្ដល់អំណាចដល់កម្មករក្នុងការតស៊ូមតិ សម្រាប់ខ្លួនគេ និងទទួលបានធនធាន។

## ចំណាប់អារម្មណ៍ក្នុងការកសាងសហគមន៍

អ្នកចូលរួមបានសម្ដែងការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការបង្កើតក្រុម ឬ បណ្ដាញសហគមន៍សម្រាប់ការជួយគ្នាទៅវិញទៅមក។ ពួកគេចង់បន្តជួបជុំ ចែករំលែកចំណេះដឹង និងគាំទ្រគ្នាទៅវិញទៅមក ក្រោយវគ្គបណ្ដុះបណ្ដាលនេះ។

## ការរៀបចំកាលវិភាគដែលគិតគូរពីគ្រួសារ និងបរិយាបន្ន

អ្នកចូលរួមជាស្ត្រីបានកត់សម្គាល់ថា ការរៀបចំកាលវិភាគដែលគិតគូរពីគ្រួសារ ដោយពិចារណាលើការទទួលខុសត្រូវថែទាំកុមារ និងកិច្ចការផ្ទះ នឹងធ្វើឱ្យពួកគេអាចចូលរួមយ៉ាងពេញលេញ។ ដើម្បីឱ្យស្ត្រីអាចចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលបាន ទាមទារឱ្យមានការគិតគូរហ្មត់ចត់ពីពេលវេលា និងបន្ទុកមើលថែកូនរបស់ពួកគេ។

# អនុសាសន៍សំខាន់ៗ

### ប្រើប្រាស់សម្ភារៈសាមញ្ញ មានរូបភាព និងងាយស្រួលយល់

- រូបភាពច្បាស់លាស់ និងអក្សរតិចតួច
- ឧទាហរណ៍ជាជំហានៗ និងការបង្ហាញជាក់ស្តែង

### អនុវត្តវិធីសាស្ត្រពង្រឹងភាពអង់អាច និងផ្តោតលើអ្នករៀន

- ការនិទានរឿង និងការរៀនសូត្រពីមិត្តភ័ក្តិ
- សកម្មភាពដែលផ្អែកលើបទពិសោធជីវិតពិត

### ពង្រឹងជំនាញហិរញ្ញវត្ថុ ឌីជីថល និងសុវត្ថិភាព

- ឧបករណ៍ និងតារាងហិរញ្ញវត្ថុដែលសាមញ្ញ
- គន្លឹះ សុវត្ថិភាពនៃប្រព័ន្ធឌីជីថល និងការយល់ដឹងអំពីការលួចបន្លំ
- ការអនុវត្ត OHS ជាក់ស្តែងដោយប្រើឧបករណ៍ការពារសុវត្ថិភាពផ្ទាល់ខ្លួន ដែលមាននៅមូលដ្ឋាន

### បណ្តាញគាំទ្រនិងការទទួលបានប្រព័ន្ធគាំទ្រផ្លូវការ

- កសាងសហគមន៍ ឬក្រុមមិត្តភ័ក្តិដែលបន្តសកម្មភាព
- ភ្ជាប់អ្នកចូលរួមទៅនឹងអង្គការផ្អែកលើសិទ្ធិ និងសេវាគាំទ្រផ្លូវការ

### ធានាការផ្តល់ជូនដែលមានបរិយាបន្ន និងឆ្លើយតបនឹងយេនឌ័រ

- កែសម្រួលសកម្មភាពសម្រាប់កម្រិតអក្ខរកម្ម អាយុ និងសមត្ថភាពផ្សេងៗគ្នា
- ការរៀបចំកាលវិភាគដែលគិតគូរពីគ្រួសារ និងការពិចារណាសម្រាប់ការគាំទ្រថែទាំកុមារ



# សូមអរគុណ